# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ០២២/២០ ក.ប/ស.ជ.ណ.ម.ក

## សេចក្តីជូនដំណឹង

## ស្តីពី

## ការធ្វើតេស្តសមត្ថភាពភាសាជប៉ុន JFT-Basic សម្រាប់ពលករជំនាញ ដើម្បីទៅធ្វើការនៅប្រទេសជប៉ុន

យោងតាមការជូនដំណឹងពីក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងទៅធ្វើការនៅប្រទេសជប៉ុន ក្នុងគម្រោងពលករជំនាញ ឱ្យបានជ្រាបថា អង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន នឹងរៀបចំការធ្វើតេស្តសមត្ថភាពភាសាជប៉ុន JFT-Basic ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

- មណ្ឌលសម្រាប់ការធ្វើតេស្តសមត្ថភាពភាសាជប៉ុន JFT-Basic មានពីរដូចខាងក្រោម៖
  
  ១. មណ្ឌលសកលវិទ្យាល័យអន្តរជាតិ ប៊ែលធី (សាខាទួលស្លែង)
  - អាសយដ្ឋាន៖ ផ្ទះលេខ២១ ផ្លូវលេខ៣៦០ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
  - លេខទូរស័ព្ទ៖ +855 78 221 222
  
  ២. មណ្ឌលវិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ (EDI)
  - អាសយដ្ឋាន៖ ផ្ទះលេខ៩A ផ្លូវលេខ៣៧០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ
  - លេខទូរស័ព្ទ៖ +855 23 966 967 / +855 12 629 768 / +855 15 729 123
- កាលបរិច្ឆេទការធ្វើតេស្ត ៖
  - ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៦ និងនៅថ្ងៃទី២៦ និងទី២៧ ខែកក្កដា ឆ្នាំ២០២០
  - នៅថ្ងៃទី១ ទី៣ ទី៧ និងទី៨ ខែសីហា ឆ្នាំ២០២០
  - នៅថ្ងៃទី១៤ ទី១៥ និងចាប់ពីថ្ងៃទី១៧ ដល់ទី១៩ និងចាប់ពីថ្ងៃទី២១ ដល់ទី២៣ ខែកញ្ញា ឆ្នាំ២០២០
- ព័ត៌មានលម្អិតអំពីការចែកពាក្យ និងការចុះឈ្មោះធ្វើតេស្ត សូមចូលមើលគេហទំព័រខាងក្រោម៖
  
  http://ac.prometric-jp.com/testlist/nc/en/index.html
- ការធ្វើតេស្តចែកជា ៤ផ្នែក (រយៈពេល៦០នាទី)៖
  
  ១. ពាក្យ (Script and Vocabulary)
  
  ២. ការសន្ទនា (Conversation and Expression)
  
  ៣. ការស្តាប់ (Listening Comprehension)
  
  ៤. ការអាន (Reading Comprehension)។

- ការប្រលងតេស្តសមត្ថភាពភាសាជប៉ុន JFT-Basic ៤ផ្នែក ខាងលើមាន ៦០សំណួរ និងរយៈពេល ៦០នាទី
- ការធ្វើតេស្តគឺធ្វើឡើងតាមរយៈប្រព័ន្ធកុំព្យូទ័រ (CBT Method)
- ពិន្ទុដែលជាប់ការប្រលងតេស្តសមត្ថភាពភាសាជប៉ុន JFT-Basic គឺចាប់ពី២០០ពិន្ទុ លើពិន្ទុសរុប២៥០
- តម្លៃចុះឈ្មោះធ្វើតេស្តៈ ២២ដុល្លារ
- **ឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់មកជាមួយរួមមានៈ**
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ
  - លិខិតឆ្លងដែន ឬ
  - ប័ណ្ណបើកបរ

**បញ្ជាក់ៈ** កាលបរិច្ឆេទនៃការធ្វើតេស្តនេះ អាចនឹងផ្លាស់ប្តូរអាស្រ័យទៅតាមស្ថានភាពជំងឺកូវីដ-១៩។ ក្នុងករណីមានការប្រែប្រួលណាមួយ ក្រសួងនឹងជូនដំណឹងបន្ថែមទៀត។

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងលេខទូរស័ព្ទ +603 76283371 (ប្រទេសជប៉ុន) រៀងរាល់ម៉ោងធ្វើការ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងចង់សុំចុះឈ្មោះធ្វើតេស្តសមត្ថភាពភាសាជប៉ុន ជ្រាបតាមការគួរ។

ថ្ងៃ ព្រហស្បតិ៍ ៤រោច ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**

-សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា(ACRA)

-សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា(MAC)

-ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់

"ដើម្បីជួយផ្សព្វផ្សាយ និងសហការ"

-ឯកសារ-កាលប្បវត្តិ